# ការស្នើសុំព័ត៌មាន
## (REQUEST FOR INFORMATION) MEDI-CAL

ថ្ងៃជូនដំណឹង៖
ករណីលេខ៖
ឈ្មោះបុគ្គលិកបម្រើការ៖
អត្តលេខបុគ្គលិកបម្រើការ៖
លេខទូរសាររបស់កម្មករ៖
លេខទូរសព្ទបុគ្គលិកបម្រើការ៖
ម៉ោងធ្វើការ៖
សេចក្ដីជូនដំណឹងអំពី:

## សូមកត់សំគាល់៖ អ្នកត្រូវអានទំព័រនេះមុនគេបង្អស់

យើងខ្ញុំត្រូវការព័ត៌មានបន្ថែមពីអ្នក ដើម្បីបញ្ចប់ការពិនិត្យសើរើសិទ្ធិទទួល Medi-Cal របស់អ្នក។ មុនយើងស្នើសុំឲ្យអ្នកផ្ដល់ព័ត៌មាន យើងបានមើលកំណត់ហេតុរបស់យើង និងគ្រប់ព័ត៌មានផ្សេងៗទៀត ដែលយើងមាន។ ការស្រាវជ្រាវរបស់យើង មិនបានផ្ដល់គ្រប់ព័ត៌មានដែលយើងត្រូវការទេ។ យើងនៅតែត្រូវការព័ត៌មានណាដែលមានគូសប្រអប់ នៅក្នុងទំព័រទាំងឡាយតទៅនេះ។

**យើងត្រូវតែទទួលព័ត៌មាននេះ ឲ្យទាន់ ។ បើមិនដូច្នោះទេ អ្នកអាចបាត់បង់អត្ថប្រយោជន៍**

**Medi-Cal របស់អ្នក!**

- ប្រើក្រដាសទម្រង់បែបបទនេះ ដើម្បីប្រមូលឯកសារ ឬព័ត៌មានដែលយើងត្រូវការ។
- លោកអ្នកមិនត្រូវការផ្ញើទម្រង់បែបបទនេះមកយើងវិញទេ។
- អ្នកអាចផ្ញើព័ត៌មាននេះមកឲ្យយើងវិញ តាមរយៈប្រៃសណីយ៍ ទូរសារ ទូរស័ព្ទ ដោយផ្ទាល់ខ្លួន ឬតាមអ៊ីនធឺណិត។ ទាក់ទងទៅខោនធីរបស់អ្នក ដើម្បីឲ្យដឹងពីរបៀបផ្ញើព័ត៌មានរបស់អ្នក តាមអ៊ីនធឺណិត។
- ស្រោមសំបុត្របិទតែមស្រាប់ ត្រូវបានផ្ដល់ឲ្យអ្នក ដើម្បីផ្ញើឯកសារ ឬព័ត៌មានត្រឡប់មកវិញ។
- សូមសរសេរលេខសំណុំរឿង ដែលមានវាយនៅខាងលើទំព័រនេះ នៅលើឯកសារណាដែលអ្នកផ្ញើមកយើង។
- ប្រសិនបើអ្នកមានសំនួរ ត្រូវការព័ត៌មានបន្ថែម ឬមិនអាចផ្ដល់ព័ត៌មានដែលយើងស្នើសុំ សូមទាក់ទងមកយើងតាមលេខទូរស័ព្ទដែលមាននៅខាងលើទំព័រនេះ។

## សំខាន់! សូមអានគ្រប់ទំព័រនៅក្នុងទម្រង់បែបបទនេះ

**សូមជួយយើងរក្សាទំនាក់ទំនងជាមួយអ្នក!**

**ទូរស័ព្ទទៅបុគ្គលិកខាងសិទ្ធិចូលរួមអ្នក បើអ្នកផ្លាស់ប្តូរអាសយដ្ឋាន ឬលេខទូរស័ព្ទ។**

**(ព័ត៌មានទាក់ទងរបស់បុគ្គលិក មានរាយនៅខាងលើទំព័រនេះ)**

**ការស្នើសុំព័ត៌មាន (REQUEST FOR INFORMATION) MEDI-CAL**

*កំណត់សំគាល់៖ យើងត្រូវការតែព័ត៌មាន ដែលមានគូសប្រអប់ **តែប៉ុណ្ណោះ**។*

## ប្រាក់ចំណូល

ព័ត៌មានអំពីប្រាក់ចំណូលរបស់អ្នក នឹងជួយយើងសម្រេចចិត្តថា តើអ្នកមានសិទ្ធិទទួល Medi-Cal ដោយឥតគិតថ្លៃ ឬតម្លៃថោក ឬមានសិទ្ធិទទួលជំនួយពី Covered California ដែលជាទីផ្សារអត្ថប្រយោជន៍សុខភាពរបស់រដ្ឋ ដែរឬទេ។

☐ សំណៅមួយច្បាប់ នៃសំបុត្របើកប្រាក់ថ្មីជាងគេរបស់អ្នក ឬសេចក្តីថ្លែងមកពីនិយោជករបស់អ្នក ស្តីពីការងាររបស់អ្នក (អ្នកមានប្រាក់បៀវត្សរ៍ប៉ុន្មានមុនដកហូតពន្ធ អ្នកត្រូវគេបើកប្រាក់ញឹកញាប់ប៉ុណ្ណា ហើយអ្នកធ្វើការប៉ុន្មានម៉ោង) សម្រាប់ការងារនីមួយៗរបស់អ្នក (បើអ្នកមានការងារច្រើនជាងមួយ) សម្រាប់៖

បើអ្នកមិនទទួលសំបុត្របើកប្រាក់ ហើយមិនអាចទទួលសេចក្តីថ្លែងមួយពីនិយោជករបស់អ្នកបានទេ

អ្នកអាចធ្វើកិច្ចការមួយដូចខាងក្រោមនេះ៖

- ផ្តល់សំណៅមួយច្បាប់នៃឯកសារបង់ពន្ធរបស់អ្នក សម្រាប់៖
- ទាក់ទងទៅបុគ្គលិករបស់អ្នក ដើម្បីបំពេញសេចក្តីថ្លែងជាសម្បថមួយ ចុះហត្ថលេខាក្រោមការប្រថុយទោសស្បថបំពាន និងចុះថ្ងៃខែឆ្នាំដោយអ្នក ស្តីថា អ្នកមានប្រាក់ចំណូលប៉ុន្មានមុនដកហូតពន្ធ អ្នកត្រូវបានគេបើកប្រាក់ជាញឹកញាប់ប៉ុណ្ណា និងអ្នកធ្វើការប៉ុន្មានម៉ោង។

☐ បើអ្នករកស៊ីដោយខ្លួនឯង ផ្តល់សំណៅមួយច្បាប់នៃឯកសារពន្ធ Schedule C ក្នុងឯកសារបង់ពន្ធដ៏ថ្មីជាងគេរបស់អ្នក **ឬ** សេចក្តីថ្លែងពីផលចំណេញ និងការខាតបង់ សម្រាប់រយៈពេលបីខែកន្លងមក សម្រាប់៖

☐ ភស្តុតាងអំពីអត្ថប្រយោជន៍និកម្មភាព ឬពិការភាពរបស់អ្នក—គឺសំណៅនៃសំបុត្របើកអត្ថប្រយោជន៍ ឬសំបុត្រមួយដែលបង្ហាញថា អ្នកបានប្រាក់ប៉ុន្មានមុនការដកហូត សម្រាប់៖

☐ ភស្តុតាងអំពីអត្ថប្រយោជន៍អតីតយុទ្ធជន (ជំនួយនិងការថែទាំ ពិការភាព ឬការចូលនិវត្តន៍)—គឺសំណៅមួយច្បាប់នៃសំបុត្របើកអត្ថប្រយោជន៍ ឬសំបុត្រផ្តល់ប្រាក់សម្រាប់៖

☐ ភស្តុតាងអំពីអត្ថប្រយោជន៍សន្តិសុខសង្គម ដែលបានទទួល៖—គឺសំណៅមួយច្បាប់នៃសំបុត្របើកអត្ថប្រយោជន៍ ឬសំបុត្រផ្តល់ប្រាក់សម្រាប់៖

☐ ភស្តុតាងអំពីប្រាក់ចូលនិវត្តន៍ ឬសោធននិវត្តន៍ ដែលបានទទួល៖—គឺសំណៅមួយច្បាប់នៃសំបុត្របើកអត្ថប្រយោជន៍ ឬសំបុត្រសែកសម្រាប់៖

☐ ព័ត៌មានអំពីស្ថានភាពបង់ពន្ធរបស់អ្នក និង/ឬស្ថានភាពបង់ពន្ធ របស់សមាជិកដទៃទៀតក្នុងបន្ទុកគ្រួសារ សម្រាប់៖

☐ បំពេញទម្រង់បែបបទដែលអមភ្ជាប់ក្នុងនេះ មានចំណងជើង "ការស្នើសុំព័ត៌មានស្តីពីពន្ធគ្រួសារ "(Request for Tax Household Information) (RFTHI) សម្រាប់៖

☐ ផ្សេង៖

**ការដកហូត៖**

☐ សំណៅមួយច្បាប់នៃសែក ឬបង្កាន់ដៃបង់ថ្លៃថែទាំកូន អាហារកិច្ចចិញ្ចឹមកូន អាហារកិច្ចចិញ្ចឹមអតីតប្រពន្ធ ឬថ្លៃធានារ៉ាប់រងសុខភាព សម្រាប់៖

☐ ផ្សេង៖

**ព័ត៌មានអំពីបុគ្គលដែលស្នើសុំ Medi-Cal**

☐ សំណៅមួយច្បាប់នៃប័ណ្ណបើកបរ California របស់អ្នក ឬ ID មានរូបថតមួយ សម្រាប់៖

☐ លេខសន្តិសុខសង្គមសម្រាប់៖

☐ សំណៅមួយច្បាប់ នៃឯកសារ ឬប័ណ្ណអន្តោប្រវេសន៍ (ថតចម្លងទាំងសងខាងនៃប័ណ្ណ ឬឯកសារ) សម្រាប់៖

ប្រសិនបើអ្នកជាជនអន្តោប្រវេសន៍ ហើយមិនមានលេខសន្តិសុខសង្គម ឬឯកសារអន្តោប្រវេសន៍ដើម្បីផ្តល់មកយើងទេ អ្នកនៅតែអាចមានសិទ្ធិទទួលសេវាសង្គ្រោះបន្ទាន់ ឬសេវាទាក់ទងនឹងការមានផ្ទៃពោះបាន។ សូមទូរស័ព្ទទៅបុគ្គលិករបស់អ្នក ដើម្បីប្រាប់យើងអំពីការផ្លាស់ប្តូរនៃស្ថានភាពអន្តោប្រវេសន៍/ចូលសញ្ជាតិរបស់អ្នក ឬបើអ្នកមិនមានលេខសន្តិសុខសង្គម ឬឯកសារអន្តោប្រវេសន៍ ដើម្បីយើងអាចបញ្ចប់ការពិនិត្យសើរើរបស់យើងបាន។

**អតីតកូនចិញ្ចឹមបណ្តោះអាសន្ន**

☐ សំណៅមួយច្បាប់ នៃឯកសារណាមួយសម្រាប់៖ ដែលបង្ហាញថា អ្នកបានស្ថិតក្នុងការចិញ្ចឹមបណ្តោះអាសន្ន ត្រឹមថ្ងៃខួបកំណើតទី 18 របស់អ្នក។ យើងស្នើសុំព័ត៌មាននេះ ដោយសារយើងមិនទាន់បានទទួលភស្តុតាង ថាអ្នកបានស្ថិតក្នុងការចិញ្ចឹមបណ្តោះអាសន្ន នៅពេលមានអាយុ 18 ឡើង។

ព័ត៌មានដែលយើងបានមើល បង្ហាញដូចតទៅ៖

**ទីលំនៅ**

☐ ការបញ្ជាក់អំពីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក (បង្កាន់ដៃបង់ថ្លៃផ្ទះ សំបុត្រទារប្រាក់ទឹកភ្លើង ។ល។)។

**ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬអចលនទ្រព្យ**

☐ សំណៅមួយច្បាប់នៃលិខិតចុះបញ្ជីរថយន្ត ឬប័ណ្ណសំគាល់កម្មសិទ្ធិទាំងអស់ (បើមានរថយន្តច្រើនជាងមួយគ្រឿង) សម្រាប់៖

☐ សំណៅមួយច្បាប់នៃរបាយការណ៍ធនាគារថ្មីជាងគេរបស់អ្នក (គណនីចរន្ត គណនីសន្សំ ។ល។) សម្រាប់៖

☐ សំណៅមួយច្បាប់នៃការធានារ៉ាប់រង ភាគហ៊ុន សញ្ញាប័ណ្ណ ឬរបាយការណ៍គណនីចូលនិវត្តន៍ សម្រាប់៖

☐ ឯកសារបញ្ជាក់អំពីទ្រព្យសម្បត្តិណាផ្សេងទៀត នៅក្នុង ឬនៅខាងក្រៅប្រទេស United States (ផ្ទះក្រៅពីទីលំនៅ ដីធ្លី ។ល។) សម្រាប់៖

☐ ឯកសារបញ្ជាក់ថា អ្នកបានលក់ ប្តូរ ឬអោយអ្នកដទៃ នូវទ្រព្យសម្បត្តិ ឬបិទគណនី សម្រាប់៖

**ពិការភាព/អសមត្ថភាព**

☐ សំបុត្រផ្តល់ប្រាក់សន្តិសុខសង្គម សម្រាប់ពិការភាព សម្រាប់៖

☐ ភស្តុតាងផ្សេងទៀត បញ្ជាក់ថាអ្នកមានពិការភាពផ្លូវកាយ ផ្លូវគំនិត ឬផ្លូវចិត្ត ដែលអាចមានរយៈពេល 12 ខែ ឬយូរជាង សម្រាប់៖

បើអ្នកគិតថា ខ្លួនអ្នក ឬសមាជិកគ្រួសារណាម្នាក់ ដែលទទួល Medi-Cal មានពិការភាព នោះសូមទាក់ទងទៅបុគ្គលិករបស់អ្នក។

☐ **ព័ត៌មានផ្សេងទៀតដែលយើងត្រូវការ៖**